សេចក្តីប្រកាសព័ត៌មាន

រដ្ឋមន្ត្រីក្រសួងការបរទេស
លោកជំទាវ **The Hon Julie Bishop MP**

ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៨

# ដំណើរការបោះឆ្នោតនៅកម្ពុជា

អូស្ត្រាលីមានក្តីបារម្ភយ៉ាងខ្លាំងចំពោះការបោះឆ្នោតជាតិឆ្នាំ ២០១៨ នៅកម្ពុជា និងបានបង្ហាញក្តីបារម្ភនេះទៅដល់រាជរដ្ឋាភិបាលកម្ពុជា។

ដំណើរការបោះឆ្នោត ដែលរាប់បញ្ចូលទាំងការរំលាយគណបក្សសង្គ្រោះជាតិ ការឃុំខ្លួនប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា ព្រមទាំងការព្យួរសិទ្ធិនយោបាយរយៈពេល៥ឆ្នាំរបស់តំណាងរាស្ត្រ និងមន្ត្រីគណបក្សសង្គ្រោះជាតិ គឺជាការបោះជំហានដើរថយក្រោយនៃដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាដែលមានរយៈពេល២៥ឆ្នាំ។

សេរីភាពនៃការបញ្ចេញមតិ និងការចូលរួម ជាសក្ខីភាពនៃសង្គមលទ្ធិប្រជាធិបតេយ្យ។ អូស្ត្រាលី មានក្តីបារម្ភចំពោះការបោះឆ្នោត ដែលស្ថិតក្រោមបរិយាកាសមួយដែលគ្រប់ភាគីគណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងស្ថាប័នសារព័ត៌មានពុំអាចដំណើរការយ៉ាងពេញ លេញ។

អូស្ត្រាលី មានការខកចិត្តដែលប្រជាពលរដ្ឋកម្ពុជាពុំអាចមានសេរីភាពពេញលេញក្នុងការ ជ្រើសរើសតំណាងរបស់ពួកគេ។

ក្នុងនាមជាមិត្តភក្តិយូរអង្វែងរបស់កម្ពុជា អូស្ត្រាលីនឹងបន្តទទូចឲ្យរដ្ឋាភិបាលកម្ពុជា បោះជំហានឈានទៅរកការគស្ល៊ូមតិនយោបាយដោយសេរី និងបើកជំហរ ដោយពុំមានការប្រើប្រាស់អំពើហិង្សា និងការគំរាមកំហែងនានា៕